**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៧៤...ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំព្រឹត្តិការណ៍អបអរសាទរ ខួប១០ឆ្នាំនៃប្រាសាទព្រះវិហារ និងខួប១ឆ្នាំនៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

នៅពហុកីឡដ្ឋានជាតិអូឡាំពិកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំព្រឹត្តិការណ៍អបអរសាទរខួប១០ឆ្នាំនៃប្រាសាទព្រះវិហារ និងខួប១ឆ្នាំនៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ៣កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨ មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

| | |
|---|---|
| ៥- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- អគ្គនាយិកាវិទ្យុ និងទូរទស្សន៍បាយ័ន | អនុប្រធាន |
| ៧- តំណាងគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ៨- តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៩- តំណាងក្រសួងព័ត៌មាន | សមាជិក |
| ១០- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១១- តំណាងក្រសួងធម្មការ និងសាសនា | សមាជិក |
| ១២- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១៣- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ១៤- ប្រធានអាជ្ញាធរជាតិព្រះវិហារ | សមាជិក |
| ១៥- ប្រធានអាជ្ញាធរជាតិសំបូរព្រៃគុក | សមាជិក |
| ១៦- អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិកអចិន្ត្រៃយ៍ |
| ១៧- អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៨- អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |

**ប្រការ២ ._**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីដឹកនាំ ចាត់ចែង និងសម្របសម្រួលដំណើរការរៀបចំព្រឹត្តិការណ៍អបអរសាទរខួប១០ឆ្នាំនៃប្រាសាទព្រះវិហារ និងខួប១ឆ្នាំនៃតំបន់ប្រាសាទសំបូរព្រៃគុក ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មានភារកិច្ចដូចខាងក្រោម៖

-ដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដី

-រៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដាពាក្យស្លោក និងការងារពាក់ព័ន្ធសម្រាប់ពិធី

-រៀបចំគម្រោងចំណាយនៃកិច្ចដំណើរការរៀបចំពិធី

-ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់

-ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ។

**ប្រការ៣ ._**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីគណៈកម្មការអន្តរក្រសួង។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១៤ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ